ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## ការប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង៨: ០០ នៅសាលសិក្ខាសាលាខាងត្បូង បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ និងថ្នាក់ដឹកនាំចាប់ពីប្រធាននាយកដ្ឋានឡើងចំនួន៤៩នាក់ ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានមានមតិស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងអង្គប្រជុំ និងបានអនុញ្ញាតឱ្យឯកឧត្តម លោកជំទាវជា អគ្គនាយក អគ្គនាយិកា និងលោកជំទាវអគ្គាធិការ រាយការណ៍អំពីលទ្ធផលការងារសម្រេចបានក្នុងខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២០ ជូនអង្គប្រជុំជ្រាប ។

បន្ទាប់ពីស្តាប់របាយការណ៍របស់អគ្គនាយកដ្ឋានទាំង៥ និងអគ្គាធិការដ្ឋានរួចមក **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំឱ្យគ្រប់អង្គភាពយកចិត្តទុកដាក់បន្តបណ្តុះបណ្តាលហ្វឹកហាត់មន្ត្រីស្រាវជ្រាវពីកម្រិតបឋមទៅកម្រិតមធ្យមក្នុងរយៈពេល៥ឆ្នាំ (២០២០-២០២៥) និងបន្តពីកម្រិតមធ្យមទៅកម្រិតអ្នកស្រាវជ្រាវជាន់ខ្ពស់ក្នុងរយៈពេល៥ឆ្នាំទៀត (២០២៥-២០៣០) និងបានជំរុញឱ្យគ្រប់អង្គភាពបន្តយកចិត្តទុកដាក់ក្នុងការរៀបចំឯកសារ សម្ភារៈបរិក្ខាជូនសមាជិកព្រឹទ្ធសភាចូលរួមប្រជុំនានាតាមរយៈវីដេអូ Conference ។

ដោយឡែក **ឯកឧត្តមអគ្គលេខាធិការ** បានរាយការណ៍ផងដែរអំពីលទ្ធផលនៃកិច្ចពិភាក្សាជាមួយតំណាងក្រុមហ៊ុន Hauwei ពាក់ព័ន្ធនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ICT ជាមួយស្ថានទូតជប៉ុនបានជួបពិភាក្សាគ្នាក្នុងការស្វែងរកជំនួយអភិវឌ្ឍស្ថាប័ន ដោយឈរលើកិច្ចសហប្រតិបត្តិការល្អ និងយូរអង្វែង ព្រមទាំងបានបង្ហាញជូនអំពីការវិវឌ្ឍន៍នៃព្រឹត្តិការណ៍ជាតិ តំបន់ និងពិភពលោក ជូនអង្គប្រជុំជ្រាប ដើម្បីជាចំណេះដឹងទូទៅក្នុងការប្រតិបត្តិការការងារប្រចាំថ្ងៃឱ្យបានកាន់តែល្អប្រសើរ និងបានជម្រាបជូនលទ្ធផលការងារដែលសម្រេចបានដូចខាងក្រោម៖

**I.លទ្ធផលការងារសម្រេចបាន៖**

**១-មុខងារនីតិកម្ម**

-បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន ០៤ច្បាប់៖

១.សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

២.សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៣.សេចក្តីព្រាងច្បាប់ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

៤.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែនស្តីពី កិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩ ។

**២-មុខងារតាមដានការអនុវត្តច្បាប់**

ក្រុមភូមិភាគទី១ បានអញ្ជើញចុះប្រមូលព័ត៌មានអំពីការងារអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋាន និងបញ្ហាប្រឈមនានា ដើម្បីត្រៀមរៀបចំវេទិកាភូមិភាគទី១នាពេលខាងមុខ នៅសង្កាត់ក្រាំងធ្នង់ រាជធានីភ្នំពេញ ។

**៣-មុខងារតំណាង**

-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងចូលរួមក្នុងពិធីផ្សេងៗរួមមាន៖

+ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពឯកឧត្តម **ស៊ិន ចិត្រា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និងសពលោក **សេង សាញ់** ចៅសង្កាត់ស្ទឹងមានជ័យ១ នៅរាជធានីភ្នំពេញ

+ចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋ មន្ត្រី និងអាជ្ញាធរមូលដ្ឋានសង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-សមាជិកព្រឹទ្ធសភា បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ចាន់ ស៊ីវ៉ាន់ថា** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល និងសពនាយឧត្តមសេនីយ៍ **ចក់ ឡេង** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ព្រមទាំងសពឧបាសកព្រឹទ្ធាចារ្យ **លឹម ណៃ** នៅខេត្តព្រះសីហនុ

-សមាជិកព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋានក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ តាកែវ កំពត កែប កំពង់ធំ មណ្ឌលគិរី បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប

-ព្រឹទ្ធសភា បានចាត់ចែងដង្វាយថ្វាយសម្តេចម៉ែក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរសង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក និងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ ១៩ (COVID-19) ។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ទើបតែងតាំងថ្មីប្រចាំប្រទេសនានាចំនួន០៩រូប ចូលជួបសម្តែងការគួរសម និងសុំអនុសាសន៍ណែនាំមុន

នឹងចេញដំណើរទៅបំពេញភារកិច្ច

-ឯកឧត្តមអនុប្រធានគណៈកម្មការទី១ បានចូលរួមប្រជុំស្តីពី ការពិគ្រោះយោបល់ជាក់ស្តែងតាមតំបន់ ការវាយតម្លៃជំងឺកូវីដ១៩ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈវីដេអូ Conference

-ឯកឧត្តមប្រធានគណៈកម្មការទី២ បានចូលរួមប្រជុំគណៈកម្មការ គោលនយោបាយ APF តាមរយៈវីដេអូ Conference

-លោកជំទាវប្រធានគណៈកម្មការទី៩ បានជួបពិភាក្សាការងារជាមួយលោកនាយកសាលាសម្ព័ន្ធភាពបារាំង ប្រចាំនៅខេត្តសៀមរាប

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយលោកអនុប្រធានក្រុមហ៊ុន Hauwei ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាស្តីពី គម្រោងសហប្រតិបត្តិការបច្ចេកទេស រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមហ៊ុន Hauwei និងលោកអនុប្រធានបេសកកម្មការទូត និងជាប្រធានទទួលបន្ទុកផ្នែកជំនួយរបស់ស្ថានទូតអូស្ត្រាលី និងតំណាងស្ថានទូតជប៉ុន ព្រមទាំងលោកនាយកសាលាសម្ព័ន្ធភាពបារាំង ប្រចាំនៅខេត្តសៀមរាប នៅសាលប្រជុំពិសេស

-មន្ត្រី APF ចូលរួមប្រជុំវីដេអូ Conference អំពីការងាររបស់គណៈកម្មការ APF ។

## ៥-មុខងារអភិវឌ្ឍស្ថាប័ន

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រឆាំងជំងឺកូវីដ១៩

-បន្តយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីជានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-ការបង្កើយគម្រោងជួសជុល និងកែលម្អអគារមួយចំនួន ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

-ការបន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធសម្លេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ និងការបោះពុម្ព

-ការបន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាពផលិតសេវានៅទាប

-ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ៖ ចំណេះដឹង ជំនាញភាសា គ្រប់គ្រង/ដឹកនាំ បច្ចេកវិទ្យាព័ត៌មាន

-សិក្សាការរៀបចំ PCA ដំណាក់កាលបន្ទាប់ពី PIC ការរៀបចំ Legal Database របស់ព្រឹទ្ធសភា

-សិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានាឱ្យបានសមស្របនឹងដំណាក់កាលថ្មី

-ការបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ដើម្បីទ្រទ្រង់ដំណើរការថវិការហូតដល់ចុងឆ្នាំ២០២០

-បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី ការឆ្លងឯកសារចនាសម្ព័ន្ធការងារចាត់តាំង និងផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០២១-២០៣០) របស់អគ្គនាយកដ្ឋានទាំង៥

-បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី បែបបទវាយតម្លៃសមត្ថភាពបុគ្គលិកជាប់កិច្ចសន្យា វាយតម្លៃតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ និងគំរូព្រឹត្តិបត្រវាយតម្លៃតាំងស៊ប់ក្នុងក្រប-ខ័ណ្ឌមន្ត្រីរាជការ

-អនុវត្តការងារមន្ត្រីរាជការ និងការរៀបចំសមាសភាពលេខាធិការដ្ឋានគណៈកម្មការទី២ និងគណៈកម្មការទី៥ ។

**៦-ការបណ្តុះបណ្តាលធនធានមនុស្ស**

បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន ០៥វគ្គ មានសិក្ខាកាមចំនួន ៥៨នាក់ ។

**II.ទិសដៅការងារសម្រាប់ខែកក្កដា ឆ្នាំ២០២០**

*១-សេវាទ្រទ្រង់មុខងារនីតិកម្ម ៖*

ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី២៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេច

វេះពន្ធនិងការគេចវេសពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងម៉ាឡេស៊ី

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និងការគេចវេសពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ ។

**២-សេវាទ្រទ្រង់មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ៖**

ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញ ជំនួបសវនាការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ។

**៣-សេវាទ្រទ្រង់មុខងារតំណាង៖**

ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ។

**៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបផ្លូវការរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានា

-ត្រៀមធនធានមនុស្ស ឯកសារ ថវិកា និងសម្ភារៈ ឆ្ពោះទៅកិច្ចប្រជុំ ASEP 11

-ត្រៀមរៀបចំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាប្រជុំតាមរយៈវីដេអូ Conference

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន ។

**៥-ការអភិវឌ្ឍស្ថាប័ន៖**

-ត្រៀមរៀបចំគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២១ លើមូលដ្ឋាននៃថវិការំកិល៣ឆ្នាំ (២០២១-២០២៣)

-ត្រៀមរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆមាសទី១ ឆ្នាំ២០២០ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ប្រជុំផ្ទងការរៀបចំគម្រោងថវិកាឆ្នាំ២០២១ព្រឹទ្ធសភា ជាមួយថ្នាក់ដឹកនាំអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា និងគណៈកម្មការទី២ព្រឹទ្ធសភា

-ត្រៀមការពារគម្រោងថវិកាឆ្នាំ២០២១ព្រឹទ្ធសភា កម្រិតបច្ចេកទេសជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-រៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធី លើមូលដ្ឋានរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានទាំង៩

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធ Online ដើម្បីជានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាព ជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃ ទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ INTERNET

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងព្រឹទ្ធសភា

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធី Eបណ្ណាល័យ និង Eបណ្ណសារ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់

-បន្តពិនិត្យ កែសម្រួល និងផ្ទងឯកសារផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានទាំង៩ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ICT អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-បន្តប្រជុំគណៈកម្មការគោលការណ៍ គោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងគ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បន្តការងារពិនិត្យសម្រេចលើការរៀបចំរចនាសម្ព័ន្ធ ការងាររចាត់តាំង និងផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់អគ្គនាយកដ្ឋានទាំង៥ ។

### សេចក្តីសន្និដ្ឋាន

ខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តការយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រឆាំងជំងឺកូវីដ១៩។ ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋានក៏មានការងារ មមាញឹកជាច្រើនលើមុខងារនីតិកម្ម ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន ០១លើក បានយ៉ាងល្អប្រសើរ ។

ទន្ទឹមនឹងនេះ លើមុខងារតំណាង បានអមដំណើរសមាជិកព្រឹទ្ធសភា ចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានខិតខំពង្រីកវិសាលភាពលើគ្រប់វិស័យ ដោយរក្សាបាននូវភាពជាដៃគូជាមួយបណ្តាប្រទេស បណ្តាសភា និងដៃគូអភិវឌ្ឍន៍សំខាន់ៗជាច្រើនទៀត។ បន្តលើកកម្ពស់ការផ្តល់សេវាស្រាវជ្រាវ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធ Online ក្នុងប្រតិបត្តិការការងារប្រចាំថ្ងៃ។ ដើម្បីសម្រេចឱ្យបានចក្ខុវិស័យរយៈពេល១០ឆ្នាំទៅមុខទៀត ក្នុងការប្រែក្លាយព្រឹទ្ធសភាឱ្យឈានឆ្ពោះទៅកាន់លក្ខន្តិកៈការងារជាសភាទំនើប អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ចប់ការកសាងក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ (២០២១-២០៣០) និងកំពុងបន្តពិនិត្យកែសម្រួលផែនការយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ និងការងាររចាត់តាំងរបស់អគ្គនាយកដ្ឋានទាំង៥ ឱ្យស្របតាមគោលការណ៍កំណែទម្រង់ និងស្ថានភាពជាក់ស្តែងរបស់ស្ថាប័ន ។

ការធ្វើវីដេអូ Conference បានក្លាយជាការពិតនៅក្នុងជីវិតការងារថ្មី សម្រាប់សមាជិកព្រឹទ្ធសភាក្នុងការងារតំបន់ និងពិភពលោក ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១.០០ព្រឹក ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល ប្រកបដោយស្មារតីទទួលខុសត្រូវ ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០

ប្រធាននាយកដ្ឋាន

បានឃើញ និងឯកភាព
អគ្គលេខាធិការ

អ៊ុំ សារិទ្ធ

បានឃើញ និងឯកភាព
អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ

ឈឹម ព្រះខ័ន

ឡាំង ថន